Bon Secours Mercy Health
បំពេញបន្ថែមលើគោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុចំពោះការថែទាំសុខភាព
សេចក្តីសង្ខេបការគណនាចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់វិក្កយបត្រជាទូទៅ (AGB)
មានប្រសិទ្ធភាពនៅថ្ងៃទី 1 ខែមីនា ឆ្នាំ 2025

អនុលោមតាមបទបញ្ញត្តិស្តីពីរតនាគារ §1.501(r)-5(a)(1) មន្ទីរពេទ្យមួយត្រូវកំណត់ចំនួនទឹកប្រាក់ដែលត្រូវគិតថ្លៃសម្រាប់ការថែទាំដែលត្រូវផ្តល់ដល់បុគ្គលណាម្នាក់ដែលមានសិទ្ធិទទួលបានជំនួយក្រោមគោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ខ្លួនមិនឱ្យលើសពីចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់វិក្កយបត្រជាទូទៅ (AGB) ក្នុងករណីសង្គ្រោះបន្ទាន់ និងការថែទាំចាំបាច់ពាក់ព័ន្ធនឹងវេជ្ជសាស្ត្រផ្សេងៗទៀត។ បទបញ្ញត្តិ §1.501(r)-5(b)(1) ផ្តល់វិធីសាស្ត្រពីរសម្រាប់មន្ទីរពេទ្យដើម្បីប្រើក្នុងការកំណត់ AGB៖ (1) វិធីសាស្ត្រពិនិត្យម៉ោងការងារ (2) វិធីសាស្ត្រទូទាត់សំណងរបស់ Medicare ឬ Medicaid។ ដូចមានចែងនៅក្នុងគោលនយោបាយជំនួយហិរញ្ញវត្ថុចំពោះការថែទាំសុខភាព (FAP) របស់ Bon Secours Mercy Health, Bon Secours Mercy Health គណនាភាគរយ AGB សម្រាប់មន្ទីរពេទ្យ Bon Secours Mercy Health នីមួយៗដោយផ្អែកលើវិធីសាស្ត្រពិនិត្យម៉ោងការងារសម្រាប់មន្ទីរពេទ្យដែលមានស្រាប់ទាំងអស់ និងវិធីសាស្ត្រទូទាត់សំណងរបស់ Medicare សម្រាប់មន្ទីរពេទ្យថ្មីណាមួយដោយគ្មានទិន្នន័យនៃការទាមទារកាលពីឆ្នាំមុន។

មន្ទីរពេទ្យ Bon Secours Mercy Health ជ្រើសរើសយកវិធីសាស្ត្រ "ពិនិត្យមើលឡើងវិញ" ដោយផ្អែកលើការទាមទារជាក់ស្តែងដែលត្រូវចំណាយទៅឱ្យមន្ទីរពេទ្យនីមួយៗ។ សូមមើលករណីលើកលែងខាងក្រោមសម្រាប់ទីតាំងមន្ទីរពេទ្យថ្មីដែលមានអាជ្ញាបណ្ណក្នុងឆ្នាំបច្ចុប្បន្ន។ ដោយអនុលោមតាម §1.501(r)-5(b)(3)(i) មន្ទីពេទ្យ Bon Secours Mercy Health គណនាភាគរយ AGB របស់ខ្លួនដោយផ្អែកលើថ្លៃសម្រាប់សេវា Medicare និងអ្នកផ្តល់ការធានារ៉ាប់រងសុខភាពឯកជនទាំងអស់ ដែលទូទាត់ថ្លៃសំណងទាមទារ ទៅឱ្យមន្ទីរពេទ្យ។ AGB សម្រាប់មន្ទីរពេទ្យនីមួយៗត្រូវបានគណនាជារៀងរាល់ឆ្នាំ ដោយបែងចែកចំនួនទឹកប្រាក់សរុបនៃសំណងទាមទារទាំងអស់សម្រាប់ការសង្គ្រោះបន្ទាន់ និងការថែទាំចាំបាច់ផ្សេងៗទៀត ដែលត្រូវបានអនុញ្ញាតដោយអ្នកធានារ៉ាប់រង Medicare និងអ្នកធានារ៉ាប់រងផ្នែកជំនួញក្នុងរយៈពេល 12 ខែមុន ដោយការបូកសរុបថ្លៃសេវាដែលពាក់ព័ន្ធសម្រាប់ការទាមទារទាំងនោះ។ សម្រាប់ឆ្នាំ 2025 រយៈពេល 12 ខែ ដែលបានប្រើសម្រាប់ការគណនា AGB របស់មន្ទីរពេទ្យនីមួយៗ គឺថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2023 ដល់ថ្ងៃទី 31 ខែតុលា ឆ្នាំ 2024។

ការគណនា AGB ត្រូវបានកំណត់សម្រាប់មន្ទីរពេទ្យនីមួយៗ។ ទាក់ទងនឹងការប្រែប្រួលបញ្ជីទូទាត់ និងអត្រាកិច្ចសន្យាថែទាំដោយមានការគ្រប់គ្រង ការគណនា AGB សម្រាប់មន្ទីរពេទ្យមានចាប់ពី 8.9% ទៅ 43.4%។ មន្ទីរពេទ្យនីមួយៗអនុវត្តភាគរយ AGB របស់ខ្លួនចំពោះការគិតថ្លៃសរុបលើផ្អែកលើមូលដ្ឋានពីមន្ទីរពេទ្យមួយទៅមន្ទីរពេទ្យ។ អត្រាភាគរយ AGB តាមមន្ទីរពេទ្យត្រូវបានភ្ជាប់ជាមួយ។

សម្រាប់ទីតាំងមន្ទីរពេទ្យថ្មីដែលមានអាជ្ញាបណ្ណក្នុងឆ្នាំបច្ចុប្បន្ន មន្ទីរពេទ្យ Bon Secours Mercy Health ប្រើវិធីសាស្ត្រទូទាត់សំណងរបស់ Medicare ដើម្បីកំណត់ AGB។ ទីតាំងមន្ទីរពេទ្យដែលប្រើវិធីសាស្ត្រទូទាត់សំណង អាចកំណត់ AGB សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ពាក់ព័ន្ធនឹងវេជ្ជសាស្ត្រផ្សេងទៀតដែលផ្តល់ទៅឱ្យបុគ្គលដែលមានសិទ្ធិទទួលបាន FAP ដោយប្រើដំណើរការទូទាត់វិក្កយបត្រ និងការសរសេរកូដដែលមន្ទីរពេទ្យនឹងប្រើ ប្រសិនបើបុគ្គលដែលមានសិទ្ធិទទួលបាន FAP គឺជាអ្នកទទួលផលថ្លៃសេវា Medicare។ ទីតាំងមន្ទីរពេទ្យនឹងកំណត់ AGB

សម្រាប់ការថែទាំតាមចំនួនទឹកប្រាក់ដែលមន្ទីរពេទ្យកំណត់ថាជាចំនួនទឹកប្រាក់សរុបដែល Medicare នឹងអនុញ្ញាតសម្រាប់ការថែទាំ (រួមទាំងចំនួនដែលនឹងត្រូវសងដោយ Medicare និងចំនួនទឹកប្រាក់ដែលអ្នកទទួលផលនឹងត្រូវទទួលខុសត្រូវផ្ទាល់សម្រាប់ការទូទាត់ជាទម្រង់នៃប្រាក់ចំណាយផ្ទាល់ខ្លួន សហធានារ៉ាប់រង និងប្រាក់ចំណាយដែលត្រូវបង់ជាមុន)។
វិធីសាស្ត្រនេះនឹងត្រូវបានប្រើសម្រាប់ឆ្នាំ 2025 សម្រាប់ Bon Secours Harbor View Medical Center។

**Bon Secours Mercy Health**
**Medicare and Commercial**
**11/1/23 ដល់ 10/31/24 ZBA's**

| **ចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់វិក្កយបត្រជាទូទៅ (AGB)** | **11/1/23 ដល់ 10/31/24**<br>**អនុញ្ញាតតែចំនួនទូទាត់រួច** |
|---|---|
| St. Elizabeth Boardman | 21.0% |
| St. Elizabeth Youngstown | 19.9% |
| St. Joseph | %18.9 |
| Allen | 25.7% |
| Lorain | 21.0% |
| Defiance | 28.1% |
| Tiffin | 33.5% |
| Willard | 39.1% |
| St. Vincent (រួមទាំង St. Anne និង St. Charles) | 15.5% |
| St. Rita's Medical Center | 20.6% |
| Springfield Regional | 19.5% |
| Urbana | 23.4% |
| Anderson | 22.6% |
| Clermont | 21.9% |
| Fairfield | 20.8% |
| Kings Mills | 22.4% |
| Jewish | 23.1% |
| West | 21.4% |
| Lourdes | 21.0% |
| Marcum Wallace | 27.8% |
| Mary Immaculate Hospital | %22.1 |
| Maryview Medical Center | 22.5% |
| Memorial Regional Medical Center | 21.2% |
| Richmond Community Hospital | 20.6% |
| St Francis Medical Center | 22.6% |
| St Mary's Hospital | 22.8% |
| Rappahannock | 43.4% |
| Southside | 8.9% |
| Southern Virginia | 10.9% |
| Southampton Hospital | 17.8% |
| St Francis Hospital | 18.5% |